## ៥. ការគ្រប់គ្រងជំងឺ

ការបាញ់ថ្នាំសម្លាប់ផ្សិត គឺជាយុទ្ធសាស្ត្រមួយដែលគេនិយមក្នុងការគ្រប់គ្រងជំងឺ SALB ។

ថ្នាំសម្លាប់ផ្សិតចាស់ៗជាច្រើន (chlorothalonil, propineb, mancozeb, benomyl) និងថ្នាំសម្លាប់ផ្សិតតាមប្រព័ន្ធ (systemic fungicides) ថ្មីៗ (triadimephon, thiophanate methyl, prochloraz, propiconazole, triadimenol និង azoxystrobin) គឺមានប្រសិទ្ធភាព ។ ថ្នាំសម្លាប់ផ្សិតទាំងនេះ ត្រូវបានបាញ់ពីលើអាកាសដោយយន្តហោះ ឬ បាញ់ពីដីដោយម៉ាស៊ីនបាញ់ថ្នាំ ។ ការប្រើថ្នាំសម្លាប់ផ្សិតតាមប្រព័ន្ធយូរៗទៅ អាចនាំឲ្យកើតមានពូជផ្សិតដែលធន់នឹងថ្នាំសម្លាប់ផ្សិត ។ កាលពីមុន ក្លូនដែលធ្លាប់ហៅថា "ក្លូនធន់" ត្រូវបានឆ្លងជំងឺនៅពេលដែលពូជថ្មីនៃផ្សិត *M. ulei* កើតឡើង ។



## ៦. ការគំរាមកំហែងនៃជំងឺ SALB នៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក

ជំងឺជាច្រើន ជាឧទាហរណ៍ ជំងឺ late blight (ដំឡូងបារាំង), ជំងឺ rust (កាហ្វេ) និងជំងឺ Dutch elm បានឆ្លងកាត់មហាសមុទ្រ និងកើតមាននៅក្នុងតំបន់ថ្មី ។ ការរាលដាលនេះ ត្រូវបានសន្មតថាតាមរយៈស្ព័រសាត់តាមខ្យល់ ឬ ការនាំចូលរុក្ខសម្ភារដែលឆ្លងជំងឺ ។ ហេតុនេះ ជំងឺ SALB គឺជាការគំរាមកំហែងមួយដល់តំបន់អាស៊ីនិងប៉ាស៊ីហ្វិក ដោយសារគមនាគមន៍កើនឡើងរវាងប្រទេសដែលមានកើតជំងឺតំបន់ (SALB) និងប្រទេសដាំដុះកៅស៊ូនៅក្នុងតំបន់ ។ គេបានព្យាករថា ដំណាំកៅស៊ូនៅអាស៊ីអាគ្នេយ៍នឹងត្រូវបានបំផ្លាញក្នុងរយៈ ៥-៧ឆ្នាំ ក្រោយពេលដែលជំងឺ SALB ត្រូវបាននាំចូល ដោយសារលំនាំដាំនៅជិតគ្នា បរិស្ថានអំណោយផលទៅនឹងជំងឺ និងក្លូនដែលងាយទទួលរងជំងឺនេះ ។៕


**វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**

អាសយដ្ឋានៈ អគារលេខ ៩ មហាវិថី ប៉ែននុត(២៨៩) សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ឬ ប្រអប់សំបុត្រលេខ ១៣៣៧ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ/ទូរសារៈ (៨៥៥) ២៣ ៨៨២ ៨៣១

សារអេឡិចត្រូនិចៈ crri@camnet.com.kh

វិបសាយៈ www.crri.com.kh



ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា


ប័ណ្ណបច្ចេកទេស

# ជំងឺជ្រុះស្លឹកអាមេរិកខាងត្បូង( SALB ) នៃដំណាំកៅស៊ូ




ការផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

ការិយាល័យដាំដុះ-ការពារ

ខែសីហា ឆ្នាំ២០១២

## ១. សេចក្ដីផ្ដើម

ជំងឺជ្រុះស្លឹកអាមេរិកខាងត្បូង (SALB) ជាជំងឺដ៏គ្រោះថ្នាក់បំផុតនៃដំណាំកៅស៊ូ ដោយសារផលបំផ្លិចបំផ្លាញរបស់វា ។ តាមសារតារ ជំងឺ SALB បានបំផ្លាញចម្ការកៅស៊ូជាច្រើន ដែលបានបង្កើតឡើងក្នុងបណ្ដាទសវត្សឆ្នាំ១៩៣០ នៅអាមេរិកកណ្ដាល និងអាមេរិកខាងត្បូង ។ បណ្ដាប្រទេសដាំកៅស៊ូនៅអាស៊ី ដែលផលិតច្រើនជាង៩០% នៃកៅស៊ូធម្មជាតិពិភពលោក មានការព្រួយបារម្ភជាខ្លាំងចំពោះការគំរាមកំហែងនៃជំងឺ SALB ។ មូលហេតុដែលនាំឲ្យមានការបារម្ភចំពោះជំងឺនេះ គឺដោយសារលក្ខខណ្ឌអាកាសធាតុនៅក្នុងប្រទេសផលិតកៅស៊ូសំខាន់ៗទាំងនោះ អាចប្រកបនឹងការបង្កជំងឺ SALB ដ៏សាហាវនេះ ។

## ២. ភ្នាក់ងារបង្កជំងឺ

ជំងឺ SALB ត្រូវបានបង្កឡើងដោយផ្សិតដែលមានឈ្មោះ *Microcyclus ulei* ។ ផ្សិតនេះបង្កើតស្ព័របីប្រភេទ ដូចជា conidia, pycnospores និង ascospores ។




## ៣. រុក្ខជាតិដែលទទួលជំងឺ

ផ្សិត *M. ulei* បង្កជំងឺតែលើពួក *Hevea* ប៉ុណ្ណោះ ។ *Hevea* មានចំនួន ១១ ប្រភេទ ប៉ុន្តែផ្សិត *M. ulei* បង្កជំងឺតែលើ *Hevea* ចំនួន ៥ ប្រភេទប៉ុណ្ណោះ គឺ *H. brasiliensis, H. spruceana, H. guianensis, H. Benthamiana* និង *H. Camporum* ។

## ៤. សញ្ញាជំងឺ

ផ្សិតនេះបង្កជំងឺតែលើផ្នែកខ្ចីនៃរុក្ខជាតិ ។



សញ្ញាដំបូងនៃការបង្កជំងឺ គឺការខូចទ្រង់ទ្រាយនៃកូនស្លឹកទាំងឡាយ ជាយថាហេតុកូនស្លឹកដែលឆ្លងជំងឺធ្ងន់ធ្ងរក៏ឡើងក្រៀមស្ងួត ហើយប្រែពណ៌ហាក់ដូចជាខ្មៅ ។



ជាលិកាស្លឹកនៅចំកណ្ដាលនៃលេស្យុង ក្លាយជារលួយ ហើយប្រែជាពណ៌សដូចក្រដាស ហើយក្រោយមកទៀតក៏រហែក ដែលបន្សល់ទុករន្ធប្រហោងនៅលើស្លឹក ។



កូនស្លឹកដែលកើតជំងឺធ្ងន់ធ្ងរ ក៏ជ្រុះមកដី រីឯទងស្លឹកនៅសល់ជាប់នឹងមែកមួយរយៈ ប៉ុន្តែពួកវានឹងជ្រុះនៅពេលបន្ទាប់ជាយថាហេតុ ។



មែកដែលឆ្លងជំងឺ អាចងាប់ពីចុង ។ ដើមដែលកើតជំងឺធ្ងន់ធ្ងរ នឹងមានកញ្ចុំមែកស្លឹកតិចជាមួយមែកងាប់ ។

ផ្សិត *M.ulei* ក៏បង្កជំងឺផងដែរនៅលើទងស្លឹក មែកខ្ចី កញ្ចុំផ្កា ផ្កា និង ផ្លែខ្ចី ។

